*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

# សុន្ទរកថា
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីប្រកាសដាក់ដំណើរការជាផ្លូវការ នូវប្រព័ន្ធចុះបញ្ជីអាជីវកម្ម
# តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន - ដំណាក់កាលទី ៣

*ទីស្តីការ ក.ស.ហ.វ., ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២៣ (រយៈពេល ១០ នាទី)*

- ***ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា;***
- ***លោក, លោកស្រី, ភ្ញៀវជាតិ និង អន្តរជាតិ, ជាទីមេត្រី!***

ខ្ញុំមានសេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ធ្វើជាអធិបតី ក្នុង **ពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ នូវប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន - ដំណាក់កាលទី ៣** នាពេលនេះ ។ ខ្ញុំសូមស្វាគមន៍ និង ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះ ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី ដែលបានឆ្លៀតពេលដ៏មានតម្លៃ ចូលរួមក្នុងពិធីដ៏មានសារៈសំខាន់នេះ ។

ខ្ញុំសូមរំលឹកថា **ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន - ដំណាក់កាលទី ១** ត្រូវបានប្រកាសដាក់ឱ្យដំណើរការ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នាថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី ដែលមានវត្តមាននៅថ្ងៃនេះ ។ ដំណាក់កាលទី ២ ត្រូវបានដាក់ឱ្យដំណើរការ នៅពីថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០២១ តាមប្រព័ន្ធអនឡាញ ដោយសារ

ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។ សម្រាប់ដំណាក់កាលទី ៣ នេះ, យើងអាចរៀបចំពិធីប្រកាសដាក់ឱ្យដំណើរការដោយផ្ទាល់ឡើងវិញ ដោយមានការអញ្ជើញចូលរួមយ៉ាងច្រើនកុះករ ជាមួយនឹងការផ្សាយបន្តផ្ទាល់ផងដែរ នៅលើបណ្តាញសង្គម ដែលការណ៍នេះ សបញ្ជាក់ឱ្យឃើញពីជោគជ័យដ៏ត្រចះត្រចង់នៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការយកឈ្នះលើសមរភូមិប្រឆាំងនឹងជំងឺកូវីដ-១៩ ។

## ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!

មុនការឆ្លងរាលដាលនៃជំងឺកូវីដ-១៩, កម្ពុជាស្ថិតនៅលើគន្លងអភិវឌ្ឍន៍ ប្រកបដោយជវភាព ។ ទោះបីជាវិបត្តិនៃជំងឺកូវីដ-១៩ បានបង្កឱ្យសេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះ, ជាលើកដំបូង, ក្នុងអត្រា -៣.១% ក្នុងឆ្នាំ ២០២០ ក៏ដោយ, កម្ពុជានៅតែអាចគ្រប់គ្រងស្ថានការណ៍បានយ៉ាងប្រសើរ និង បានក្លាយជាប្រទេសឈានមុខមួយ នៅលើសកលលោក ក្នុងការគ្រប់-គ្រងជំងឺកូវីដ-១៩ តាមរយៈការចាក់វ៉ាក់សាំងដោយឥតគិតថ្លៃ ជូនប្រជាជន ដែលបង្កើតបាននូវភាពស៊ាំសហគមន៍រឹងមាំ ព្រមទាំងបានអនុញ្ញាតឱ្យកម្ពុជា អាចបើកប្រទេស និង សកម្មភាពសង្គម-សេដ្ឋកិច្ចពេញលេញឡើងវិញយ៉ាងរហ័ស ។ ថ្មីៗនេះ, កម្ពុជាក៏ទទួលបានកិត្តិយសដ៏ល្បីរន្ទឺ តាមរយៈការទទួលបាននូវជោគជ័យដ៏ត្រចះត្រចង់ជាប្រវត្តិសាស្ត្រ គួរជាទីមោទនៈបំផុត ក្នុងការបំពេញតួនាទីជាប្រធានប្តូរវេន និង ជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន លើកទី ៤០ និង ទី ៤១ និង កិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅក្នុងឆ្នាំ ២០២២ ព្រមទាំងការទទួលធ្វើជាម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍កីឡា ស៊ីហ្គេម លើកទី ៣២ និង អាស៊ានប៉ារ៉ាហ្គេម លើកទី ១២ ឆ្នាំ ២០២៣ ដែលទើបត្រូវបានបិទបញ្ចប់នាពេលថ្មីៗ បន្ទាប់ពីការរង់ចាំអស់រយៈពេល ៦៤ ឆ្នាំ ។

សមិទ្ធផលទាំងនេះ បានបង្ហាញយ៉ាងច្បាស់ថា កម្ពុជាមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា និង អាចចូលរួមក្នុងកិច្ចការតំបន់ និង សកល បានប្រកបដោយប្រសិទ្ធភាព, ស្មើសិទ្ធិ និង ស្មើភាព, ដោយសារភាពជាអ្នកដឹកនាំដ៏វៃឆ្លាត របស់រាជរដ្ឋាភិបាល, ក្រោមមគ្គុទ្ទេសក៍ដ៏ភ្លឺស្វាង របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**, ក្នុងការដាក់ចេញនូវវិធានការឆ្លើយតបដ៏ត្រឹមត្រូវ, ទាន់ពេល និង ចំទិសដៅ ។

យ៉ាងណាមិញ, រាជរដ្ឋាភិបាលយល់ច្បាស់ថា ផ្លូវនៃដំណើរទៅមុខរបស់យើង ពិតជាមិនងាយស្រួលនោះទេ ។ ជាក់ស្តែង, ស្លាកស្នាមនៃវិបត្តិជំងឺកូវីដ-១៩ មិនទាន់ផុតរលត់

ទាំងស្រុងនៅឡើយ ស្របពេលដែលបញ្ហាប្រឈមជាសកលផ្សេងទៀត កើតមានជាបន្ត-បន្ទាប់ ។ ស្ថិតក្នុងបរិការណ៍ដែលពោរពេញដោយភាពមិនប្រាកដប្រជាខ្ពស់នាបច្ចុប្បន្ន និង ទៅអនាគត, កម្ពុជាពិតជាមានភាពចាំបាច់ ក្នុងការពង្រឹងភាពប្រកួតប្រជែង និង កសាងភាពធន់សង្គម-សេដ្ឋកិច្ច ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងវិបត្តិណាមួយ ដែលអាចកើតមានជាយថាហេតុ ។ ក្នុងនោះ, រាជរដ្ឋាភិបាលបានកំណត់ការធ្វើឌីជីថលូបនីយកម្ម និង បរិវត្តកម្មឌីជីថល ជាអាទិភាពគន្លឹះមួយ ដែលមានសក្តានុពលខ្ពស់ ក្នុងការជំរុញឱ្យមានការបង្កើតគំរូសេដ្ឋកិច្ចថ្មី, ការបង្កើនផលិតភាពក្នុងគ្រប់វិស័យ និង ការធានាបាននូវកំណើនសេដ្ឋកិច្ចជារួម ។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយរយៈពេលវែងចំនួន ២ គឺ ៖ **«ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥» និង «គោលនយោបាយរដ្ឋាភិបាលឌីជីថល ២០២២-២០៣៥»** ជាមួយនឹងចក្ខុវិស័យកសាងរដ្ឋាភិបាល, សេដ្ឋកិច្ច និង សង្គមឌីជីថល វៃឆ្លាត និង រស់រវើក ។

## *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

ការរៀបចំប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន គឺជាការកែទម្រង់មួយដ៏សំខាន់ ក្នុងដំណើរឆ្ពោះទៅរកការកសាងរដ្ឋាភិបាល, សេដ្ឋកិច្ច និង សង្គមឌីជីថល ។ ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន - ដំណាក់កាលទី ១ បានអនុញ្ញាតឱ្យគ្រប់ក្រុមហ៊ុន-សហគ្រាស អាចចុះបញ្ជីជាកញ្ចប់ជាមួយនឹងក្រសួង-ស្ថាប័ន ចំនួន ៣ រួមមាន ៖ ក្រសួងពាណិជ្ជកម្ម, អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងអាចចុះបញ្ជីជាគម្រោងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (Qualified Investment Project - QIP) ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។ ក្រសួងមហាផ្ទៃក៏បានផ្តល់កិច្ចសហការ ក្នុងការផ្តល់ទិន្នន័យអត្តសញ្ញាណកម្ម សម្រាប់ការ-បង្កើតគណនីរួម (Single Sign-On) ចូលប្រើប្រាស់ផតថលផងដែរ ។ ដំណាក់កាលទី ២ បានអនុញ្ញាតឱ្យក្រុមហ៊ុន-សហគ្រាស អាចស្នើសុំអាជ្ញាបណ្ណ, វិញ្ញាបនបត្រ និង លិខិតអនុញ្ញាតជំនាញផ្សេងៗ នៅក្រសួង-ស្ថាប័ន ចំនួន ៤ បន្ថែម រួមមាន ៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, ក្រសួងទេសចរណ៍, ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍, និង និយ័តករអាជីវកម្មអចលនវត្ថុ និង បញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ។

*[សូមផ្អៀងផ្អាត់ តាមការអាន]*

ដំណាក់កាលទី ៣ នេះ គឺជាបង្គោលចរថ្មីមួយទៀត នៃការរៀបចំប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដោយមានការចូលរួមពីក្រសួង-ស្ថាប័ន រហូតដល់ ១២ ដូច ត្រូវបានបង្ហាញលម្អិត នៅក្នុងរបាយការណ៍របស់ **ឯកឧត្តមបណ្ឌិត ផាន់ ផល្លា** និង បទបង្ហាញរបស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** ។ ក្នុងនោះ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ ក្រសួង-ស្ថាប័ន ចំនួន ៧ នឹងអាចដំណើរការចាប់ពីថ្ងៃនេះតទៅ, ខណៈដែលប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័ន ចំនួន ៥ ទៀត នឹងអាចដាក់ឱ្យដំណើរការ នៅចុងខែ កក្កដា ឆ្នាំ ២០២៣ ខាងមុខនេះ ។

ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំក៏សូមជម្រាបជូនអង្គពិធីថា ការរៀបចំប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ទាំង ៣ ដំណាក់កាលកន្លងមក តែងមានការកាត់បន្ថយនូវ នីតិវិធី, ថិរវេលា និង ថវិកា ក្នុងគោលដៅផ្តល់ភាពងាយស្រួលឱ្យបានជាអតិបរមា ដល់ការ-បង្កើតអាជីវកម្មស្របច្បាប់របស់វិស័យឯកជន ។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលតែងកែសម្រួល និង បន្ថែមមុខងារថ្មីៗជាបន្តបន្ទាប់ នៅលើថ្នាលបច្ចេកវិទ្យាព័ត៌មាន, ជាពិសេស មុខងារ ដែលអនុញ្ញាតឱ្យធុរជន និង វិនិយោគិន អាចលើកឡើងអំពីបញ្ហាប្រឈម និង ផ្តល់មតិ-យោបល់កែលម្អ ក្នុងន័យស្ថាបនា ។

បច្ចុប្បន្ននេះ, ប្រព័ន្ធចុះបញ្ជីអាជីវកម្ម ទាំង ៣ ដំណាក់កាល ត្រូវបានដាក់ឱ្យអនុវត្តលើ **ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា** (ឬ ហៅកាត់ថា ថ្នាល CamDX) ។ ថ្នាល CamDX នេះ គឺជា ថ្នាលបច្ចេកវិទ្យាព័ត៌មានឈានមុខមួយនៅកម្ពុជា ដែលទើបទទួលបានជ័យលាភី «**ការសម្រប ខ្លួនប្រើប្រាស់បច្ចេកវិទ្យាបើកចំហកូដ**» (Open Source Adaptation of the Year) ពីកម្មវិធី ពានរង្វាន់អនាគតនៃរដ្ឋាភិបាល (Future of Government Awards) ប្រចាំឆ្នាំ ២០២២ ។ ជាមួយនឹងការដាក់ឱ្យដំណើរការនូវដំណាក់កាលទី ៣ នៅថ្ងៃនេះ, ក្រសួង-ស្ថាប័ន ដែល ប្រើប្រាស់ថ្នាល CamDX ដើម្បីផ្តល់សេវាសាធារណៈ នឹងមានចំនួនសរុប ១៩ ។

## *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

មុននឹងបញ្ចប់, ខ្ញុំសូមកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះក្រុមការងារអន្តរក្រសួង រៀបចំប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន, ជាពិសេស **អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** និង **មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី** «

**តេជោ**» ដែលបានខិតខំសម្របសម្រួលជាមួយគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ទាំងផ្នែកនីតិវិធី និង បច្ចេកទេស, ដើម្បីរៀបចំកិច្ចការដ៏មានសារៈសំខាន់នេះ ឱ្យសម្រេចបានជោគជ័យ តាំងពីដំណាក់កាលទី ១ រហូតដល់ដំណាក់កាលទី ៣ ។ ខ្ញុំក៏សូមថ្លែងអំណរគុណ និង វាយតម្លៃខ្ពស់ចំពោះក្រសួង-ស្ថាប័នទាំង ១២ ដែលបានចូលរួមផ្តល់កិច្ចសហការយ៉ាងសកម្ម ធ្វើឱ្យដំណាក់-កាលទី ៣ នេះ សម្រេចបានលទ្ធផលល្អ គួរជាទីមោទនៈ ។

ខ្ញុំសូមលើកទឹកចិត្តឱ្យក្រុមការងារអន្តរក្រសួង បន្តរៀបចំកិច្ចការនេះ ប្រកបដោយស្មារតីបុរេសកម្ម និង អន្តរសកម្ម សំដៅពង្រីកវិសាលភាពនៃការរៀបចំ ឱ្យគ្របដណ្តប់ដល់សេវាសំខាន់ៗ និង ចាំបាច់ផ្សេងទៀត ក្នុងគោលបំណងលើកកម្ពស់បរិយាកាសធុរកិច្ចកម្ពុជាឱ្យបានកាន់តែប្រសើរបន្ថែមទៀត ។ ខ្ញុំក៏សូមលើកទឹកចិត្តឱ្យធុរជន និង វិនិយោគិនទាំងអស់ចូលរួមទាញយកអត្ថប្រយោជន៍ឱ្យបានជាអតិបរមា ពីថ្នាលបច្ចេកវិទ្យាព័ត៌មាននេះ, ទាំងការ-ប្រើប្រាស់សេវា, ទាំងការផ្តល់មតិស្ថាបនាល្អៗ, ដើម្បីបន្តអភិវឌ្ឍថ្នាល ឱ្យកាន់តែមានប្រសិទ្ធ-ភាព និង ងាយប្រើប្រាស់ ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី និង ភ្ញៀវកិត្តិយសទាំងអស់ ប្រកបដោយសុខភាពល្អ និង ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ចរៀងៗខ្លួន ព្រមជាមួយនឹងសេចក្តីចម្រើនគ្រប់ប្រការ ក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព ។

ជាមួយនឹងការអនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុត ពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, ខ្ញុំសូមប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ នូវ «**ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន - ដំណាក់កាល ទី ៣**» ចាប់ពីពេលនេះតទៅ ៕

***សូមអរគុណ!***